# មេរៀនទី ៣៧: ទេវតាមកសួរសុខទុក្ខលោកអ័ប្រាហាំ

## លោកុប្បត្តិ ១៨:១-១៩:២៩

**គោលបំណង៖** ព្រះធ្វើនូវរឿងអស្ចារ្យជាច្រើន។

**ខគម្ពីរចងចាំ៖ ទំនុកតម្កើង ៩៥:៣** *“ដ្បិតព្រះអម្ចាស់ជាព្រះដ៏ប្រសើរឧត្ដម ព្រះអង្គជាព្រះមហាក្សត្រដ៏ខ្ពង់ខ្ពស់លើសព្រះនានា”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវគឺការអស្ចារ្យដ៏ធំបំផុតដែលព្រះជាម្ចាស់បានធ្វើ។ ព្រះអង្គបានផ្តល់ឱ្យយើងនូវជីវិតអស់កល្បទាំងដែលយើងត្រូវស្លាប់នៅក្នុងអំពើបាបទៅវិញនោះ! តើអ្នកបានទទួលស្គាល់ការអស្ចារ្យដែលបានកើតឡើងក្នុងជីវិតអ្នកយ៉ាងដូចម្តេច? សូមក្រលេកមើលពីការអស្ចារ្យដែលនៅជុំវិញអ្នក មិនមែនទាល់តែជារឿងធំឬក្នុងស្ថានភាពដ៏អស្ចារ្យនោះទេ ប៉ុន្តែសូមមើលទាំងការដែលតូចៗផងដែរ៖ ដែលរួមមានពន្លឺថ្ងៃរះដ៏ស្រស់ស្អាត, ស្នាម-ញញឹមរបស់ទារកតូចៗ, ឬក៏មនុស្សដែលព្យាយាមអត់ទោសឱ្យគ្នា និងទទួលបានសេចក្តីស្រឡាញ់ជាដើម។ សូមទូលសូមដល់ព្រះឱ្យជួយយើងអាចមើលឃើញនូវការអស្ចារ្យដែលទ្រង់ផ្តល់មកជារៀងរាល់ថ្ងៃ ហើយជួយយើងឱ្យមានសេចក្តីជំនឿរឹងមាំ នៅពេលដែលយើងជួបនូវរឿងដែលយើងគិតថាយើងមិនអាចធ្វើបាន។

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២.លោកតាអ័ប្រាហាំ ៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** **«បញ្ជូនកែវទឹក»**

**សម្ភារៈដែលត្រូវការ៖** កែវ និងទឹក

១.ចែកកុមារជាបីក្រុម ហើយឲ្យពួកគេអង្គុយជាជួរ

២. ឲ្យកែវមួយដែលមានទឹកពេញ។ ពួកគេត្រូវព្យាយាមបញ្ជូនកែវដែលមានទឹកនោះទៅកុមារបន្ទាប់ ដែលនៅពីក្រោយគេដោយប្រើដៃទាំងពីរ។ ពួកគេត្រូវតែព្យាយាមមិនឲ្យខ្ទាយទឹកចេញពីកែវនោះទេ។




៣. ក្រុមណាដែលអាចបញ្ជូនកែវទឹក ហើយនៅសល់ទឹកច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាគឺពិតជាអស្ចារ្យណាស់ដែលគេមិនបានធ្វើឲ្យខ្ទាយទឹកនៅពេលដែលគេបញ្ជូនកែវទឹកនោះ។ ប៉ុន្តែព្រះបានធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនជាងនេះសម្រាប់ពួកយើង។

**៤. ការណែនាំមេរៀន**

តើនរណាជាមនុស្សមានឥទ្ធិពលបំផុតដែលអ្នកធ្លាប់ជួប? ហេតុអ្វីបានជាអ្នកគិតថាម្នាក់នោះមានអំណាច ? តើគឺដោយព្រោះតែគេអាចលើករបស់ធ្ងន់ៗបាន? ឬក៏ដោយសារពួកគេមានលុយច្រើន? ទោះបីជាមនុស្សមាន

អំណាចប៉ុណ្ណាក៏ដោយ ក៏អំណាចរបស់ពួកគេនៅតែមានដែនកំណត់ដែរ។ ពួកគេមិនអាចហោះ ឬដកដង្ហើមនៅក្រោមទឹក ឬធ្វើឱ្យរឿងដែលមិនអាចទៅរួចកើតឡើងបានឡើយ។ អ្នកដែលមានអំណាចបំផុតក្នុងលោកគឺព្រះ! ថ្ងៃនេះ យើងនឹងសិក្សាអំពីព្រះដ៏មានអំណាចរបស់យើង ដែលបានធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនសម្រាប់បុរសម្នាក់ដែលមានឈ្មោះថាអ័ប្រាហាំ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អ័ប្រាហាំនិងក្រុមគ្រួសាររបស់គាត់រស់នៅក្នុងវាលរហោស្ថាន ហើយវាជារឿងកម្រណាស់ដែលមានភ្ញៀវណាធ្វើដំណើរឆ្លងកាត់ទីនោះ។ ការធ្វើដំណើរឆ្លងកាត់វាលរហោស្ថានមិនមែនជារឿងដែលងាយស្រួលនោះទេ។ ដូច្នេះហើយទើបពួកគេមានទំនៀមទម្លាប់យកចិត្តទុកដាក់យ៉ាងល្អបំផុតចំពោះភ្ញៀវទាំងឡាយណាដែលចូលមកលេងពួកគេ។

ប្រជាជននៅជំនាន់នោះគេរស់នៅក្នុងត្រសាលធ្វើជាផ្ទះរបស់ពួកគេ។ ថ្ងៃមួយនៅពេលដែលអ័ប្រាហាំកំពុងអង្គុយនៅមាត់ទ្វារត្រសាលរបស់គាត់។ នៅខាងក្រៅត្រសាលគឺពិតជាមានអាកាសធាតុក្តៅខ្លាំងណាស់។ អ័ប្រាហាំបានឃើញបុរស៣នាក់កំពុងឈរក្បែរត្រសាលរបស់គាត់។ គាត់មិនស្គាល់ថាពួកគេជាអ្នកណានោះទេ ប៉ុន្តែនោះគឺជាព្រះជាម្ចាស់ដែលបានមកលេងនឹងគាត់។ តើវាមិនអស្ចារ្យទេឬ?

អ័ប្រាហាំប្រញាប់ចេញទៅទទួលរាក់ទាក់បុរសទាំងបីនាក់នោះ។ គាត់ថែមទាំងផ្តល់អាហារ និងកន្លែងសម្រាកសម្រាប់ពួកគេ ថែមទាំងអញ្ជើញពួកគេចូលមកស្នាក់នៅក្នុងត្រសាលរបស់គាត់ទៀតផង។ បន្ទាប់មកអ័ប្រាហាំបានទៅប្រាប់សារ៉ាដែលជាប្រពន្ធរបស់គាត់ពីភ្ញៀវទាំងបី ហើយប្រាប់ឱ្យនាងរៀបចំធ្វើម្ហូបសម្រាប់ពួកគេផងដែរ។ សារ៉ាក៏បានរៀបចំដុតនំ ហើយអ័ប្រាហាំបានរៀបចំសាច់សម្រាប់ធ្វើម្ហូប។

នៅពេលដែលម្ហូបអាហារបានរៀបចំរួចរាល់ អ័ប្រាហាំបានលើកយកមកជូនភ្ញៀវរបស់គាត់។ ពេលដែលពួកគេកំពុងញ៉ាំអាហារពួកគេបានសួរថាសារ៉ានៅឯណា។ អ័ប្រាហាំបានប្រាប់ពួកគេថានាងនៅខាងក្នុងត្រសាល ។ បន្ទាប់មកពួកគេក៏បានប្រាប់អ័ប្រាហាំថា ដល់ពេលពួកគេត្រលប់មកម្តងទៀតនៅឆ្នាំក្រោយ អ័ប្រាហាំនិងសារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំក្រោយ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលព្រះបានសន្យាថាអ័ប្រាហាំ និងសារ៉ានឹងមានកូនប្រុសម្នាក់។ ឥលូវនេះពួកគេទាំងពីរនាក់មានវ័យកាន់តែចាស់ណាស់ទៅហើយក្នុងការដែលអាចមានកូនបាននោះ។ អ័ប្រាហាំមានអាយុ ៩៩ ឆ្នាំ ហើយ សារ៉ាមានអាយុ ៨៩ ឆ្នាំ។ សម្រាប់មនុស្ស គឺវាហាក់ដូចជារឿងដែលមិនអាចទៅរួចទាល់តែសោះ ដែលពួកគេអាចមានកូនបាននៅក្នុងវ័យចំណាស់នោះ។ ប៉ុន្តែព្រះបានសន្យាថាពួកគេនឹងមានកូននៅឆ្នាំក្រោយនេះ។ តើវាមិនមែនជារឿងដែលអស្ចារ្យទេឬអី?

សារ៉ាកំពុងស្តាប់នូវការសន្ទនារបស់ព្រះនិងអ័ប្រាហាំ។ នៅពេលនាងឮថាព្រះបានសន្យាថានាងនឹងមានកូនម្នាក់នាងក៏បានសើចក្នុងចិត្ត។ នេះគឺដោយព្រោះថាដំណឹងនេះគឺពិតជាអស្ចារ្យណាស់ ដែលនាងមិនអាចជឿថាអាចទៅរួចនោះឡើយ។ ព្រះបានជ្រាបថាសារ៉ាកំពុងលួចសើច ហើយទ្រង់ក៏មានបន្ទូលទៅអ័ប្រាហាំថា “ ហេតុអ្វីបានជាសារ៉ាសើចដូច្នេះថា ដែលចាស់ប៉ុណ្ណេះហើយតើនឹងមានកូនដែរឬ? តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើត

ដែរឬអី ដល់វេលាកំណត់នោះអញនឹងមកឯឯង លុះគ្រប់ខែហើយសារ៉ានឹងបង្កើតបានកូនប្រុស១”(**លោកុប្បត្តិ ១៨:១៣-១៤**)។ ហើយការនោះគឺពិតជាបានកើតឡើងមែន។ នៅឆ្នាំបន្ទាប់សារ៉ាបង្កើតបានកូនប្រុសម្នាក់! ព្រះបានធ្វើការដែលមិនអាចទៅរួចឱ្យកើតឡើងបានចំពោះ អ័ប្រាហាំ និងសារ៉ា! តើវាមិនមែនជារឿងដ៏អស្ចារ្យទេឬអី?

មនុស្សយើងមិនអាចធ្វើនូវរឿងគ្រប់យ៉ាងបានទេ។ យើងមិនអាចហោះលើអាកាសបានបើសិនជាគ្មានជំនួយពីគ្រឿងម៉ាស៊ីន។ យើងមិនអាចដកដង្ហើមនៅក្នុងទឹកបានទេបើសិនជាគ្មានបំពង់អុកស៊ីសែន។ ប៉ុន្តែព្រះគឺខុសពីយើង។ ទ្រង់អាចធ្វើនូវរឿងគ្រប់យ៉ាង គ្មានអ្វីដែលព្រះមិនអាចធ្វើទៅរួចបានឡើយ។ នេះជាមូលហេតុតែមួយគត់ដែលយើងត្រូវថ្វាយបង្គំព្រះ គឺដោយព្រោះទ្រង់ជាព្រះដែលមានអំណាច ហើយអាចធ្វើគ្រប់ការទាំងអស់បាន។ តើព្រះបានធ្វើនូវរឿងអស្ចារ្យអ្វីសម្រាប់ជីវិតរបស់អ្នក?

## ៦. សំនួរពិភាក្សា

១. តើអ្នកណាបានមកលេងនឹងលោកអ័ប្រាហាំ? *ទេវតាបីអង្គ*

២. តើពួកគេបានសន្យាអ្វីជាមួយនឹងអ័ប្រាហាំ? *សារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំក្រោយ*

៣. តើហេតុអ្វីបានការសន្យានេះហាក់ដូចជារឿងដែលមិនអាចទៅរួច?
*អ័ប្រាហាំមានអាយុ ៩៩ ឆ្នាំ ហើយសារ៉ាមានវ័យ ៨៩ ឆ្នាំហើយ*

៤. ហេតុអ្វីបានជាព្រះអាចធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនបាន? *ទ្រង់ជាព្រះដែលមានអំណាច*

៥. តើរឿងអស្ចារ្យអ្វីដែលព្រះអាចធ្វើសម្រាប់អ្នក? *សូមទុកឱ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ច្រៀងតាមព្យញ្ជនៈ»

១. ចែកកុមារជា៣ក្រុមស្មើគ្នា ហើយឱ្យគេអង្គុយជាមួយគ្នា

២. រើសតំណាងក្រុមម្នាក់ពីក្រុមនីមួយៗមកប៉ាវ។ ក្រុមដែលឈ្នះនឹងរើសចម្រៀងមួយបទមកច្រៀងមួយប្រយោគ។ នៅពេលដែលច្រៀងចប់មួយប្រយោគហើយ ក្រុមបន្ទាប់ត្រូវជ្រើសរើសបទចម្រៀងណាក៏បានដែលចាប់ផ្តើមដោយប្រើព្យញ្ជនៈដែលក្រុមមុនបានបញ្ចប់នោះ។




ឧទាហរណ៍៖ គឺជាការល្អដែលសរសើរព្រះ (ព្រះ {ព} ->ព) បទបន្ទាប់អាចជា ព្រះអម្ចាស់យើងល្អណាស់។

៣. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាគឺពិតជាអស្ចារ្យខ្លាំងណាស់ដែលកុមារអាចស្វែងរកបទចម្រៀងដែលចាប់ផ្តើមដោយប្រើព្យញ្ជនៈដែលក្រុមមុនបានបញ្ចប់។ ព្រះរបស់ពួកយើងគឺពិតជាមានព្រះចេស្តាខ្លាំងណាស់ ដែលព្រះទ្រង់អាចធ្វើរឿងដ៏អស្ចារ្យជាច្រើននៅក្នុងជីវិតរស់នៅរបស់យើង!

## ៨. ខគម្ពីរចងចាំ ទំនុកតម្កើង ៩៥:៣

## ៩. ហត្ថកម្ម «ទេវតាមកលេងនឹងលោកអ័ប្រាហាំ»



**សម្ភារៈដែលត្រូវការ៖** សូមបោះពុម្ពក្រដាហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត
១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌។ ផាត់ពណ៌រូបត្រសាលផងដែរ។
២. កាត់រូបត្រសាល និងកាត់បន្ទាត់ចន្លោះកណ្ដាល ហើយបិតភ្ជាប់ពីលើរូបសារ៉ា ធ្វើដូច្នេះនៅពេលដែលយើងបើកសន្លឹកដែលកាត់ចន្លោះកណ្ដាល នោះអ្នកនឹងឃើញរូបសារ៉ានៅក្នុងត្រសាល។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ទេវតាមកលេងនឹងលោកអ័ប្រាហាំ









**សម្ភារៈដែលត្រូវការ៖** សូមបោះពុម្ពក្រដាហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌។

ផាត់ពណ៌រូបត្រសាលផងដែរ។

២. កាត់រូបត្រសាល និងកាត់បន្ទាត់ចន្លោះកណ្ដាល ហើយបិតភ្ជាប់ពីលើរូបសារ៉ា ធ្វើដូច្នេះនៅពេលដែលយើងបើកសន្លឹក

